# ៦~រឿង ទេវតាសែកសោយ

កាលពីព្រេងនាយ មានមនុស្សកំសត់ពីរនាក់ប្ដីប្រពន្ធ មានកូនប្រុសមួយ ។ កូននោះកើតឡើងវេលាណា មានទេវតាអាក្រក់មកថែរក្សាសែកសោយ ។ តាំងពីទេវតាអាក្រក់មកសែកសោយក្មេងនោះថ្ងៃណា ឪពុកម្ដាយស្លាប់ចោលអស់ទៅ ។ ក្មេងនោះនៅជាមួយនឹងជីដូនៗ ក៏ថែរក្សាដរាបដល់អាយុ២០ឆ្នាំ ។ ថ្ងៃ១ក្មេងនោះចូលទៅព្រៃដើម្បីរកអុសកំពុងតែកាប់ឧស មានទេវតាមួយអង្គទៀតជាទេវតាល្អជួយអោយចំរុងចំរើនយសស័ក្តិ ភោគសម្បត្តិ ។ ទេវតានេះនិយាយនឹងទេវតាអាក្រក់ថា "តាំងពីអ្នកឯងចូលមករក្សាមនុស្សនេះកាលណា ម្ដាយឪពុកគ្នាស្លាប់ចោលអស់ ហើយគ្នាក្រលំបាកពន់ពេកឃើញថារិទ្ធិអ្នកឯងពូកែមែន" ។ ទេវតាអាក្រក់និយាយតបវិញថា "អ្នកជឿថាអំណាចខ្ញុំពូកែទេ ?" ។ ទេវតាល្អឆ្លើយថា "ខ្ញុំជឿហើយប៉ុន្តែខ្ញុំសូមរក្សាមនុស្សនេះម្ដង" ។ ទេវតាអាក្រក់ ព្រម បើកអំណាចអោយទេវតាល្អថែរក្សាហើយហោះទៅ ។ ទេវតាល្អបណ្ដាលចិត្តមនុស្សនោះ កំពុងតែកាប់ឧសក៏ដាក់ដឹងចុះ ហើយភ្ញាក់ខ្លួនព្រើតលោតិតថា "ឱអញ បើអញរស់នៅគ្រាន់អញនឹងរកស៊ីចិញ្ចឹមជីវិតជីដូនអញ បើប្រសិនជាអញស្លាប់ទៅ តើបានអ្នកណានឹងរកស៊ីចិញ្ចឹមជីដូនអញទៀត បើដូច្នេះអញគិតទៅនិយាយបបួលយាយអញទៅនៅធ្វើខ្ញុំសេដ្ឋីគ្រាន់តែសុំបាយគេស៊ីប្រហែលជាគេព្រមហើយ" គិតតែប៉ុណ្ណោះក៏លែងកាប់ឧស ត្រឡប់ទៅផ្ទះវិញទៅដល់និយាយប្រាប់ជីដូនតាមដំណើរសព្វគ្រប់ដែលខ្លួនបានគិតកាលទៅកាប់ឧស ។ ជីដូនបានស្ដាប់ហើយក៏ចូលចិត្តព្រមតាមចៅ ។

ជីដូននិងចៅក៏នាំគ្នាដើរទៅផ្ទះមហាសេដ្ឋី ដល់ចូលទៅក្នុងកំពែងរបងហើយទៅអង្គុយបត់ជើងនៅមាត់ជណ្ដើរមហាសេដ្ឋី ។ លុះបន្តិចទៅមហាសេដ្ឋីប្ដីប្រពន្ធនាំគ្នាចេញមកក្រៅ ក្រឡេកទៅឃើញអ្នកទាំងពីរនាក់អង្គុយ ក៏សួរថា "ឯងមកនេះមានប្រាថ្នាអ្វី ?" ។ បុរសកំសត់នោះឆ្លើយជំរាបទៅសេដ្ឋីថា "ខ្ញុំពីរនាក់ជីដូននិងចៅនេះ មកសុំ

នៅធ្វើជាខ្ញុំបម្រើលោក គ្រាន់តែយកបាយចិញ្ចឹមជីវិត" ។ មហាសេដ្ឋីស្តាប់ហើយឆ្លើយថា "អើឯងនៅចុះ " ។ បុរសនោះជម្រាបទៅមហាសេដ្ឋីថា "សូមលោកមេត្តាអោយខ្ញុំនៅបម្រើខាងលើផ្ទះបាយហើយនឹងផ្ទះធំ " ។ មហាសេដ្ឋីព្រម ។ ទើបយាយចាស់នោះសុំគ្រាន់តែដេញមាន់ទា កុំអោយស៊ីស្រូវកាលណាគេយកស្រូវទៅហាល ។ បុរសនោះខំយកចិត្តទុកដាក់បម្រើសេដ្ឋី មិនអោយទាស់ចិត្តបន្តិចសោះ ។ មហាសេដ្ឋីមានចិត្តអាណិតស្រឡាញ់រាប់អាន លុះយូរទៅប្រមាណជា ៣-៤ឆ្នាំ បុរសនោះសុំមហាសេដ្ឋីទៅនៅឃ្វាលក្របីវិញដល់ទៅនៅឃ្វាលក្របី ផ្លាស់អស់ពួរខ្សែចាស់ៗទាំងប៉ុន្មានជួសជុលក្រោលអោយស្អាតល្អឡើងក្របីទាំងអស់ចំនួន ១០០០ក្បាល ។ ដល់យូរទៅមហាសេដ្ឋីប្តីប្រពន្ធនិយាយគ្នាថា "តាំងពីអានេះទៅឃ្វាលក្របី យើងមិនដែលទៅមើលវាម្តងសោះ ដូច្នេះត្រូវយើងនាំគ្នាទៅមើលម្តង ក៏នាំប្តីប្រពន្ធទៅលុះទៅដល់ មើលទៅក្របីខ្សែពួរ និងក្រោលពេញចិត្តទាំងអស់ ក៏ត្រឡប់មកវិញនិយាយគ្នាថា "អានេះជាមនុស្សល្អ កាលដែលខ្ញុំយើងវារក្សាពីមុនមក មិនដែលមានប្រដាប់សម្រាប់ក្របីថ្មីយ៉ាងនេះទេ ឥឡូវនេះមានព្រម អានេះជាមនុស្សចិត្តត្រង់នឹងចៅហ្វាយនាយ" ។

បុរសនោះទៅឃ្វាលក្របីរាល់ថ្ងៃ មានកាលមួយថ្ងៃនោះ ពេលល្ងាចដេញក្របីត្រឡប់មកក្រោលវិញ មកដល់ត្រពាំងមួយដេញក្របីចុះទៅក្នុងត្រពាំងទៅជាន់លើដុំមាសនៅក្នុងបឹងនោះ បែរទៅខាងណាក៏សុទ្ធតែមាសពេញបឹងទាំងអស់ ។ បុរសថា "ដុំថ្មអ្វីច្រើនម្លេះប៉ះជើងស្ទើរស្លាប់ហើយ " ថាហើយក៏លូកទៅយកដុំមាសមួយដុំមកថា "អញយកដុំថ្មនេះ ទៅផ្ញើយាយអញព្រោះថ្មនេះល្អ " ។ បុរសនោះដេញក្របីយកមកក្រោលរួចហើយក៏យកដុំមាសនោះទៅអោយជីដូនៗបានឃើញដុំមាសហើយសួរថា "ចៅយកពីណាមកយកទៅវិញទៅ យាយមិនហ៊ានយកទេដុំមាសអ្វីធំម្លេះ" ។ បុរសដឹងជាដុំមាសដូច្នោះហើយក៏យកទៅទុកក្នុងបឹងវិញ ចំណាំកន្លែងទុកនោះរួចត្រឡប់មកវិញ ។

ថ្ងៃក្រោយមកព្រះមហាក្សត្រទ្រង់ល្បងចិត្តពួកសេនាបតី ទ្រង់មានព្រះបន្ទូលទៅនឹងអាមាត្យថា "អ្នកឯងទៅប្រាប់សេនាបតីទាំង ៤ថា ល្ងាចនេះអោយដេកចាំព្រះបរម



រាជវាំងនៅចុងព្រះរាជរោង " ។ អាមាត្យនាំយកព្រះបន្ទូលទៅជម្រាបសេនាបតីទាំង៤តាមដំណើរ ។ សេនាបតីទាំងនោះក៏រៀបខ្លួនមកដេកតាមព្រះរាជឱង្ការពេលមកដេកនោះមិនគិតប្រុងប្រយ័ត្នសោះគិតតែពីដេកទល់ភ្លឺ ។ លុះយប់ជ្រៅស្ងាត់ ស្តេចទ្រង់យាងមកទតសេនាបតីទាំង ៤ នោះឃើញដេកទាំងអស់គ្នាក៏ទ្រង់យាងត្រឡប់ទៅក្រឡាព្រះបន្ទំវិញ ដល់ព្រឹកឡើងទ្រង់មានព្រះបន្ទូលអោយចាប់សេនាបតីទាំងនោះយកទៅកាប់ចោលទៅ ។ លុះល្ងាចក្រោយទៀតទ្រង់មានព្រះបន្ទូលអោយហៅមហាសេដ្ឋីទាំង ៤ អោយមកដេកដូចមុន ។ មហាសេដ្ឋីដែលជាចៅហ្វាយបុរសកំសត់នោះភ័យណាស់ព្រោះមិនដឹងជាមានរឿងអ្វីបានជាស្តេចអោយសម្លាប់សេនាបតីទាំង ៤នោះ ឥឡូវដល់មកខ្លួនទៀតថា មុខជាស្លាប់ហើយកូនប្រពន្ធទាំងប៉ុន្មានយំសោកអស់គ្នា។ លុះបន្តិចទៅឮទៅដល់បុរសកំសត់ៗក៏ឡើងមកសួរថា "ហេតុម្តេចបានជាយំសោកយ៉ាងនេះ ? " ។ មហាសេដ្ឋីប្រាប់ទៅតាមរឿង ។ បុរសថា "បើដូច្នេះខ្ញុំសូមទៅដេកជំនួស " ។ មហាសេដ្ឋីឮដូច្នេះហើយក៏អរណាស់ អោយរកសំពត់អាវល្អយកមកអោយបុរសកំសត់នោះស្លៀកដោយគិតថា មុខជាស្លាប់ហើយ ។ លុះបុរសរៀបខ្លួនស្រេច នឹងទៅដេកចាំវាំងជាមួយពួកមហាសេដ្ឋីទៀត តែពេលទៅនោះបុរសនោះយកទាំងដាវមួយជាមួយផងទៅដល់ហើយក៏ដេក។ ពួកមហាសេដ្ឋីឯទៀតគេនៅអង្គុយនិយាយគ្នាលេង លុះដល់យប់ជ្រៅទើបនាំគ្នាដេកអស់ទៅ ។ បុរសនោះដឹងថាគេដេកស្ងាត់ ក៏ក្រោកឡើងអង្គុយម្នាក់ឯង ។ លុះយប់ជ្រៅស្ងាត់ស្តេចទ្រង់ចេញមកដូចមុនទៀត មកដល់ចុងព្រះរាជវាំងបុរសនោះក្រឡេកឃើញទាញដាវបានដេញកាប់ ធ្វើជាកាប់ផុតៗស្តេចរត់រួចទៅ ។ ក្នុងមួយយប់នោះសម្តេចចេញមក ៣ដង ។ បុរសនោះដេញកាប់ទាំង៣ដងស្តេចទ្រង់រត់ទៅវិញ ។ លុះព្រឹកឡើងស្តេចទ្រង់មានព្រះបន្ទូលអោយចាប់សេដ្ឋីទាំង ៣នាក់ ដែលដេកនោះយកទៅកាប់ចោល ហើយទ្រង់មានព្រះបន្ទូលអោយហៅបុរសកំសត់នោះទៅទ្រង់មានព្រះបន្ទូលសួរបុរសកំសត់ថា "ឯងជាសេដ្ឋីឈ្មោះអ្វី?" ។ បុរសកំសត់ក្រាបទូលថ្វាយ "ទូលព្រះបង្គំជាខ្ញុំជាកូនមហាសេដ្ឋីឈ្មោះនោះ" ។ ស្តេចមានព្រះបន្ទូលអោយ

ទៅហៅមហាសេដ្ឋី ដែលជាចៅហ្វាយ បុរសកំសត់នោះមកទ្រង់មានព្រះបន្ទូលសួរថា "នេះជាកូនអ្នកឯងមែនឬអ្វី ? " ។ មហាសេដ្ឋីក្រាបទូលឆ្លើយទទួលថា "កូនមែន" ស្ដេចមានព្រះបន្ទូលថា "បើកូនមហាសេដ្ឋីឯង អញសុំធ្វើជាកូនអញ " ។មហាសេដ្ឋីក៏ថ្វាយបុរសនោះទៅស្ដេចហើយក្រាបបង្គំលាទៅវិញ ស្ដេចមានព្រះរាជបុត្រីមួយព្រះអង្គ ក៏ទ្រង់រៀបផ្សំផ្គុំនឹងបុរសកំសត់នោះជាប្ដីប្រពន្ធទៅ ហើយអភិសេកអោយឡើងសោយរាជ្យសម្បត្តិ ដោយអំណាចទេវតាល្អចុះមកសែកសោយថែរក្សា ។ លុះសោយរាជ្យយូរទៅស្ដេចបុរសនឹកឃើញដល់ទៅមាស ដែលនៅក្នុងបឹងត្រាស់បង្គាប់ទៅមហាសេដ្ឋីឪពុកអោយទៅដឹកមាសនោះមកដាក់ឃ្លាំងទុក ។

មានថ្ងៃមួយស្ដេចបុរសនោះចង់ចេញទៅកាន់ចុងព្រះរាជរោង អោយសេនាបតីគាល់ ក៏ទៅទូលស្ដេចឪពុក ៗទ្រង់ហាមថា "ឯងជាតិជារាស្ដ្របើចេញទៅត្រូវយកមហេសីទៅផង " ។ ស្ដេចបុរសទ្រង់យាងចេញទៅកាន់ចុងព្រះរាជរោងជាមួយអគ្គមហេសី និងនាហ្មឺនទាំងពួងគាល់ត្រៀបត្រា ។ វេលានោះទេវតាអាក្រក់ដែលរក្សាបុរសនោះអំពីដើមត្រឡប់មកវិញ ក៏ជួបនឹងទេវតាល្អហើយនិយាយថា "ឥឡូវនេះអ្នករក្សាមនុស្សនេះតាំងពីនៅលំបាក ទាល់តែបានធ្វើស្ដេចថែមទៀត នេះឃើញថា អំណាចអ្នកពូកែមែន បើដូច្នេះអញចេញទៅអោយខ្ញុំរក្សាម្ដងវិញ " ។ ទេវតាល្អប្រគល់ស្ដេចកំសត់អោយទៅទេវតាអាក្រក់ ហើយហោះទៅ ។ ពេលនោះមានភ្លៀងផ្គរ ទេវតាអាក្រក់ក៏បណ្ដាលចិត្តស្ដេចបុរសនោះមួយរំពេច ស្ដេចនោះមិនបានជាគិត លោមានព្រះបន្ទូលចំពោះមុខពួកនាហ្មឺន ដែលគាល់ត្រៀបត្រាថា "អញឮផ្គរលាន់ ស្រណោះកាលនៅឃ្វាលក្របីពីដើមណាស់ " ត្រាស់តែប៉ុណ្ណេះមហេសីក៏ស្ទុះរត់ទៅរកព្រះបិតា ហើយក្រាបទូលថ្វាយ "ព្រះបិតាមិនគួរអោយខ្ញុំម្ចាស់ទៅអោយមនុស្សឃ្វាលក្របីនេះសោះ ខ្ញុំម្ចាស់លែងយកហើយ ព្រោះវានិយាយចំពោះមុខនាហ្មឺនដែលគាល់ត្រៀបត្រាថា "ឮផ្គរលាន់ស្រណោះកាលនៅឃ្វាលក្របីពីដើម ខ្ញុំម្ចាស់ខ្មាសពួកនាហ្មឺនសព្វមុខមន្ត្រីណាស់ ខ្ញុំម្ចាស់មិនយកជាប្ដីទេ" ។ស្ដេចបិតាឮដូច្នោះក៏អោយចាប់ស្ដេចនោះយកទៅដាក់គុកទៅ ។

ដាក់គុកបានពាក់កណ្ដាលថ្ងៃ ទេវតាល្អដែលរក្សាមនុស្សនោះត្រឡប់មកវិញ ។ ហើយនិយាយទៅនឹងទេវតាអាក្រក់ថា "អ្នកមានរិទ្ធិណាស់ចូលមករក្សាភ្លាមស្ដេចបុរសបានជាប់គុកភ្លាមដូច្នេះអ្នកអញ្ជើញទៅចុះទុកអោយខ្ញុំរក្សាវិញ" រួចហើយទេវតាល្អក៏បណ្ដាលចិត្តស្ដេចបុរសៗនឹកឃើញភ្លាមថា "អញមិនគួរភ្លាត់សំដី អោយទាល់តែជាប់គុកសោះ ប៉ុន្តែគ្មានអ្នកណាដឹងថា អញជាប់គុកនៅឡើយទេ ដូច្នេះអញបង្គាប់ទៅសេដ្ឋីឪពុកអញ អោយយកមាសដែលយកពីក្នុងបឹងនោះដំធ្វើរូបក្របី ១០០ដាក់ជើងពានមាស១០០អោយយកមកអោយអញក្នុងថ្ងៃស្អែកនេះពីព្រឹក " គិតតែប៉ុណ្ណោះក៏ប្រើមេគុកអោយទៅប្រាប់សេដ្ឋីថា "ស្ដេចមានព្រះបន្ទូលថា អោយយកមាសដំធ្វើរូបក្របី ១០០ដាក់លើជើងពានមាស១០០ ហើយយកទៅថ្វាយស្ដេចកន្លែងទ្រង់ " ។ សេដ្ឋីឮហើយក៏ហៅជាងទាំងពួងអោយធ្វើក្នុង១យប់ ទាល់តែហើយ លុះព្រឹកឡើងអោយពួកខ្ញុំស្រីសេដ្ឋី ១០០នាក់ កាន់ទូលយកទៅថ្វាយក្នុងព្រះរាជវាំង ។ ស្ដេចបិតាក្មេកទតមកឃើញអោយអាមាត្យរត់ទៅមើល ។ អាមាត្យមកក្រាបទូលវិញ ទ្រង់មានព្រះបន្ទូលអោយហៅអ្នកទូលក្របីនោះមក ហើយទ្រង់មានព្រះបន្ទូលសួរថា "នាងឯងរាល់គ្នាយកក្របីមាសនេលទៅណា ? " ។ ស្រីទាំងនោះទូលថា "ខ្ញុំម្ចាស់យកមកថ្វាយព្រះអង្គ " ។ ស្ដេចទ្រង់ជ្រាបទ្រង់អោយហៅព្រះរាជបុត្រីជាមហេសីស្ដេចកំសត់អោយចេញមកមើល ហើយមានព្រះបន្ទូលថា "កូនអើយ! ដែលប្ដីឯងថា ស្រណោះកាលឃ្វាលក្របីនោះមិនមែនក្របីសត្វនោះទេ គឺរូបក្របីមាសនេះឯង កូនមើលក្របីនេះចុះ ណ្ហើយកូនកុំខឹងនឹងប្ដីយកប្ដីវិញទៅ " ។ មានព្រះបន្ទូលតែប៉ុណ្ណោះ ក៏ទ្រង់អោយទៅដោះស្ដេចបុរសកំសត់មកហើយទ្រង់អភិសេកនឹងនាងជាព្រះរាជបុត្រី អោយឡើងសោយរាជ្យសប្បាយរៀងទៅ ព្រមទាំងយាយជាមាតាបុរសនោះផង ។

**រិទ្ធិនៅទេវតាប្រាជ្ញានៅមនុស្ស**